ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

ឯការបណ្តឹងឧទ្ធរណ៍

សំណុំរឿងបណ្តឹងឧទ្ធរណ៍

លេខ : ២០៤

ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៨

សាលដីកា

លេខ : ២៣០

ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ម៉ែន ស៊ិន ជាចៅក្រម

៣- លោក ប្រាក់ គឹមសាន ជាចៅក្រម

៤- លោក សោម សិរិវឌ្ឍ ជាចៅក្រម

៥- លោក ស៊ិន ទឹម ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងមហាអយ្យការ

លោក ម៉ែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក ពីសាលដីកាលេខ ២១៧ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៩៨ នៃសំណុំរឿងបណ្តឹងឧទ្ធរណ៍លេខ ២៧០ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងខ្មាស់បណ្តឹងសាទុកឈ្មោះ ហួត ស្រៀត អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅ ផ្ទះលេខ ៣១៨អឺ១ ក្រុមទី៤ ផ្លូវ ៩៣ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ថៅ សេន "ស" ម្តាយឈ្មោះហួត ភន "ស"។

និងចុងចម្លើយបណ្តឹងសាទុកឈ្មោះ មាស អឿ ភេទស្រី អាយុ៧០ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅ ភូមិខ្លាត្បូង ឃុំបឹងក្រាញ់ជើង ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ តូច មាស "ស" ម្តាយឈ្មោះ អៅ "ស" ។

ឈ្មោះ មាស អឿ បានផ្ទេរសិទ្ធិអោយកូនឈ្មោះ មាស ស៊ីវុន ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារដីភូមិទំហំ ១៤៥៨ម$^{២}$

តាមបណ្តឹងសាទុកលេខ ១១៨ ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ១៩៩៨ របស់ អ្នកស្រី ហួត ស្រៀត បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ២១៧ ចុះថ្ងៃទី១២

ខែ ឧសភា ឆ្នាំ ១៩៥៨ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២០៥ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ១៩៥៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៥.៣.៥៦ របស់លោកស្រី ហួត ស្រៀត ថា ខ្លួនសុំប្តឹងទាមទារដីភូមិទំហំ ១.៤៩៨ម² ពីចុងចម្លើយដែលត្រូវជាម្តាយក្មេកឈ្មោះ មាស អេវ៉ី ដោយសំអាងថា ក្នុងឆ្នាំ ១៩៥០ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះមាសសាត់ដែលត្រូវជាកូនរបស់ចុងចម្លើយ ហើយចុងចម្លើយបានប្រគល់ដីភូមិមកអោយខ្លួនទាំងពីរនាក់ប្តីប្រពន្ធក្រោយមកខ្លួនទាំងពីរនាក់បានដាំដំណាំជីកស្រះអោយធំជ្រៅ និង ធ្វើរបងព័ទ្ធជុំវិញដីភូមិនេះទៀតផង ចំពោះឈ្នួលអស់ ៦តម្លឹងមាស ។ លុះដល់ពាក់កណ្តាលឆ្នាំ ៥៥ ប្តីខ្លួនក៏បានស្លាប់ទៅស្រាប់តែចុងចម្លើយបានមកទាមទារយកដីភូមិនោះពាក់កណ្តាលវិញ ខ្លួនបានយល់ព្រមប្រគល់អោយត្រឹមដីភូមិចាស់ ចុងចម្លើយក៏យល់ព្រមយក លុះក្រោយមកទៀតចុងចម្លើយបានទាមទារយកដល់ទៅពាក់កណ្តាលស្រះវិញ ប៉ុន្តែខ្លួនពុំព្រមទេ ។

បានឃើញសាលក្រមលេខ ១១៩ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៥៦ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹងរបស់អ្នកស្រី ហួត ស្រៀត "ដើមចោទ" ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៥៦ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ ប្រគល់ដីទំនាស់ដែលមានទំហំ ១៤៩៨ម² ត្រឹមមាត់ស្រះពីខាងលិចទៅកើត ស្ថិតនៅភូមិខ្នាចត្បូង ឃុំបឹងក្រាញ់ជើង ស្រុកសំរោង ខេត្តតាកែវ អោយទៅអ្នកស្រី ហួត ស្រៀត ជាកម្មសិទ្ធិតទៅតាមមាត្រា ៦២ ,១៩៥ ,២០០ នៃច្បាប់ភូមិបាល ។

៣_ បង្គាប់អោយគូភាគីបំពេញលិខិតកាន់កាប់ដីធ្លីតាមច្បាប់ ។

៤_ បង្គាប់អោយអ្នកស្រីមាសអេវ៉ីបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ៊ីង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ និង ប្រាក់ស៊ើបអង្កេត ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះបានដកយកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើផុតឧទ្ធរណ៍បង្គាប់អោយចុងចម្លើយបង់ប្រាក់ ៧.០០០រៀល នេះទៅដើមចោទវិញ និងអោយចុងចម្លើយបង់ពន្ធសមាមាត្រ ១ភាគរយលើថ្លៃដីទំនាស់ ០៤តម្លឹងមាស ។ ប្រាក់ ១ភាគរយ នេះ ៨០ភាគរយ សំរាប់ថវិការដ្ឋ និង ២០ភាគរយ សំរាប់រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសកម្ពុជា ។

សាលក្រមនេះដំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០១ខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៨ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ របស់អ្នកស្រី មាស អឿ ដែលប្ដឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ ១១៩ ចុះថ្ងៃទី ២៦ ខែ ធ្នូ - ឆ្នាំ ១៩៩៦ របស់តុលាការខេត្តតាកែវ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីកាត្រៀមលេខ ០៩ ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ របស់ សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១- អោយភូមិបាលស្រុកសំរោង ខេត្តតាកែវ ចុះវាស់វែងដីទំនាស់ និង ធ្វើគំនូសប្លង់អោយបានច្បាស់លាស់ បញ្ជាក់អំពីទទឹង បណ្ដោយ នៃដីទំនាស់នេះ នៅខាងជិតស្រះ និងដីដែលមានស្រះ "ស្លូមទឹមតាមគំនូសភ្ជាប់មកជាមួយដែលមាននៅក្នុងសំណុំរឿងក្ដី" ហើយអោយចុះហត្ថលេខា និង ត្រា ព្រមទាំងដាក់ថ្ងៃ ខែ នៅលើប្លង់នោះផង ។

២- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។

បានឃើញសាលដីកាលេខ ២១៧ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១- ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ របស់ឈ្មោះ មាស អឿ ទុកជាត្រឹមត្រូវតាមទម្រង់ និង នីតិច្បាប់ ។

២- បដិសេធសាលក្រមលេខ ១១៩ ចុះថ្ងៃទី ២៦-១២-៩៦ របស់តុលាការខេត្តតាកែវ ចោលជាអសារបង់ ។

៣- បដិសេធដីកាលេខ ២៣ ចុះថ្ងៃទី ២៩-១២-៩៤ របស់អភិបាលស្រុកសំរោងចោលជាអសារបង់ ។

៤- ប្រគល់ដីទំនាស់ត្រឹមដើមត្នោតមកជិតស្ថិតនៅភូមិខ្នាចត្បូង ឃុំបឹងត្រាញ់ជើង ស្រុកសំរោង ខេត្តតាកែវ អោយទៅឈ្មោះ មាស អឿ កាន់កាប់ជាកម្មសិទ្ធិដីដែលនៅសល់ពីនេះ គឺចាប់ពីដើមត្នោតទៅកើត ប្រគល់អោយឈ្មោះ ឡួត ស្រៀត កាន់កាប់ជាកម្មសិទ្ធិ ។ តាមមាត្រា ១៩៣ , ១៩៥ នៃច្បាប់ភូមិបាលតាមប្រពៃណី និង សមធម៌ ។

៥- អោយឈ្មោះ ឡួត ស្រៀត បង់ប្រាក់ប្រដាប់ក្ដី ជាន់សាលាឧទ្ធរណ៍ចំនួន - ១៣.០០០រៀល គឺពន្ធចុះបញ្ជីក្ដី និង ពន្ធថ្លឹង ២.៨៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ជើងប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០រៀល និង អាជ្ញាធរតុលាការ៥.០០០- រៀល ។ កាលបើសាលដីកានេះចូលជាស្ថាពរ បង្គាប់អោយឈ្មោះ ឡួត ស្រៀត និងមាសអឿ បង់ពន្ធសមាមាត្រ ១ភាគរយ លើតម្លៃដីដែលត្រូវប្រគល់ ។

៦- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១១៨ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៨៨ របស់អ្នកស្រី ហួត ស្រៀត បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេច នៃសាលដីកាលេខ ២១៧ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៨៨ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៨៨ របស់អ្នកស្រី ហួត ស្រៀត ។

បានឃើញសារណាតបចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ១៩៨៩ របស់អ្នកស្រី មាស ស៊ីវន ។

បានស្តាប់រព្វការហើរបស់ចៅក្រមរព្វការហើ

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ ឃើញថាមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ហួត ស្រៀត ជាដើមចោទ និងជាម្ចាស់បណ្តឹងសាទុក្ខ បានថ្លែងឆ្លើយនៅពេលសវនាការថា : ខ្លួនមិនសុខចិត្តព្រោះសាលាឧទ្ធរណ៍កាត់ក្តីអោយខ្លួនមិនយុត្តិធម៌ ព្រោះថាដីនេះពីមុនជាចំណែកដីដែលអាជ្ញាធរភូមិ ឃុំ អោយអ្នកទាំងពីររស់នៅក្រោយមកគាត់បានប្រគល់ដីនេះអោយប្តី ប្រពន្ធ របស់ខ្លួនកាន់កាប់ ។ ខ្លួនក៏បានជីកស្រះទឹក និង ដាំដំណាំស្វាយ ស្វាយចន្ទី ពុទ្រា ។ លុះពេលប្តីខ្លួនស្លាប់ភ្លាមគាត់ក៏ទាមទារយកវិញ ។ ហើយដីដែលសាលាឧទ្ធរណ៍កាត់អោយម៉ែរបស់ខ្លួនវាសម្លុមហើយ តែគាត់នៅតែពុំព្រមទៀត ដីរបស់ខ្លួនគឺចាប់ពីមាត់ស្រះទៅរហូត តែពេលនេះម្តាយក្មេកខ្លួនស្លាប់ហើយ ដូច្នេះខ្លួនសុំទាមទារកាន់កាប់ដីទាំងអស់វិញ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី មាស ស៊ីវន ជាចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខ បានថ្លែងឆ្លើយនៅពេលសវនាការថា : ដីនេះប្អូនខ្លួនបានទៅអង្វរខ្លួនថា សុំដីនេះដើម្បីធ្វើចេតិយអោយម៉ែ ហើយវាបានជីកស្រះនេះតពីដីរបស់ខ្លួន និង បានដាំពុទ្រា ស្វាយ ព្រមទាំងបានពីទូរបងដីវិញ ហើយវាក៏ស្លាប់ទៅ ។ តែពេលនេះម្តាយខ្លួនក៏បានស្លាប់ទៅទៀត ដូចនេះខ្លួនសុំទាមទារយកដីរបស់ខ្លួនវិញ ឯដីរបស់គេដែលម្តាយខ្លួនអោយគេ អោយគេយកវិញចុះ ឯដីរបស់ខ្លួនខ្លួនយកវិញ ។

លោក អ៊ុក វ៉ាន់ដេត ជាមេធាវីការពារអោយដើមចោទ និង ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា : នៅឆ្នាំ ១៩៨០ នាង ហួត ស្រៀត បានរៀបការជាមួយប្តីនាងយ៉ាងត្រឹមត្រូវ ហើយម្តាយរបស់នាងក៏បានប្រគល់ដីនេះទៅអោយកូនប្រសារគឺតាំងពីឆ្នាំ ១៩៨០ រហូតដល់ឆ្នាំ ១៩៨៥ លោក តាយ មាស អៀន បានពោលថាកូនគាត់ស្លាប់ហើយ គាត់សុំទាមទារយកដីនេះវិញ ។ គាត់ធ្វើដូច្នេះវាខុសនឹងច្បាប់ ២០៤ នៃច្បាប់ភូមិបាល សុំតុលាការពិចារណាផងចុះតាយ មាស អៀ បានស្លាប់ហើយដីនេះក៏មិនទាន់បានប្រគល់អោយអ្នកណាដែរ ហេតុនេះសូមតុលាការជួយពិចារណា និង រកយុត្តិធម៌អោយកូនក្តីខ្លួនផង ។

---៥---

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- ឃើញថា : បណ្តឹងសាទុក្ខលេខ ១១៨ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ១៩៩៨ របស់អ្នកស្រី ឃួត ស្រៀត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- ឃើញថា : ការដែលសាលាឧទ្ធរណ៍ប្រគល់ដីទំនាស់ចាប់ពីដើមត្នោតមកលិចអោយទៅសពលោកឃាយ មាន សឿ ដោយពុំបានកំណត់អំពីទីតាំងដើមត្នោត និង បរិមាណដីដែលភាគីម្នាក់ៗត្រូវបានប៉ុន្មានផងទេនោះ ពុំទាន់មានលក្ខណៈវិនិច្ឆ័យសមរម្យនៅឡើយទេ ។

- ឃើញថា : អ្នកស្រី ឃួត ស្រៀត ថ្វីបើប្តីអ្នកស្រីទទួលមរណៈភាពក៏ពិតមែន ប៉ុន្តែកូនម្នាក់ក៏នៅជាទាយាទនៃសពនេះដែរ ដែលគប្បីតុលាការពិចារណាអំពីផលប្រយោជន៍នៃកុមារនេះ និង អំពីការដែលប្តីប្រពន្ធ ឃួត ស្រ៊ាត បានបំពេញកន្លងមកលើដីទំនាស់ និង ដើម្បីរួបរួមសង្គមសុខុមាល ។

- ឃើញថា : សាលដីការឧទ្ធរណ៍លេខ ២១៧ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូចនេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលេខ ១១៨ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់អ្នកស្រី ឃួត ស្រៀត ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការឧទ្ធរណ៍លេខ ២១៧ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣_ បដិសេធសំណុំរឿងរដ្ឋប្បវេណីលេខ ២០៤ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ១៩៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី ហួត ស្រៀត បានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធភ្ជឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,
- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុបចំនួន_ ១៩.០០០រៀល ហើយត្រូវអោយអ្នកស្រី ទាស ស៊ីវន សងប្រាក់ ១៩.០០០រៀល នេះ ទៅអ្នកស្រី ពួត ស្រៀត វិញ ។

៥_ សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ ។